# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ០៩៦ ទស.ណ.ទសភ

CAMBODIA
Kingdom of Wonder
feel the warmth

ថ្ងៃ ពុធ ១០ កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២១

### ជម្រាបជូន

### ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ ÷** ការបន្តពង្រឹងវិធានការបិទផ្អាកអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន) និងការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់ជាប់ជាប្រចាំ។

**យោង ÷** - ប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពី ការផ្ទេរប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ ទៅឱ្យរដ្ឋបាលរាជធានីខេត្ត

- សេចក្តីជូនដំណឹងលេខ ១២៩ សជណអរហ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការបិទ KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក)
- សេចក្តីជូនដំណឹងលេខ ១៣៦ សជណអជឧ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពី ស្នើចាត់វិធានការបិទអាជីវកម្ម KTV ក្លឹបកំសាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក) នៅតាមមូលដ្ឋានអាជីវកម្មដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ ជាបណ្តោះអាសន្ន
- សេចក្តីជូនដំណឹងលេខ ១៥២ សជណអរហ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការបិទអាជីវកម្មបៀរហ្គាឌិន នៅទូទាំងប្រទេសជាបណ្តោះអាសន្ន
- សេចក្តីជូនដំណឹងលេខ ២៦០ សជណអគឧ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាល ដើម្បីទប់ទល់ការរីករាលដាលនៃជំងឺកូវីដ១៩ ចំពោះមូលដ្ឋានអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន)
- សេចក្តីជូនដំណឹងលេខ ៧១០ សជណអគឧ ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការបន្តបិទសកម្មភាព KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន)
- ស្ថានភាពផ្ទុះឡើងនៃការឆ្លងរីករាលដាលជំងឺកូវីដ១៩ព្រឹត្តិការណ៍សហគមន៍ ២០ ខែកុម្ភៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងទេសចរណ៍ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** ជ្រាបថា ដើម្បីបន្តយ៉ាងសកម្មក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ (COVID-19) ពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ មូលដ្ឋានអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន) ត្រូវបន្តរក្សាការបិទផ្អាកសកម្មភាពអាជីវកម្មឱ្យបានម៉ឺងម៉ាត់ ខ្ជាប់ខ្ជួនជាប្រចាំរហូតដល់មានការសម្រេច និងជូនដំណឹងជាថ្មី។

អាស្រ័យហេតុនេះសូម **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានីខេត្ត** ត្រូវបន្តជំរុញការបិទ និងត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន)ឱ្យបានម៉ឺងមាត់ ជាប្រចាំ ដោយអនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)
- មន្ទីរទេសចរណ៍រាជធានី ខេត្ត "ដើម្បីជ្រាប"
- ឯកសារ-កាលប្បវត្តិ